**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៩៩៤ ព.ណ.[illegible]

ថ្ងៃព្រហស្បតិ៍ ១កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែសីហា ឆ្នាំ២០១៩ នឹងត្រូវលក់ ៣.៨៦០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៧៦០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែសីហា ឆ្នាំ២០១៩** នឹងចុះមក ៣.៧០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៦០០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | **Average MOPS** | ០,៤៤២៤ ដុល្លារ | ០,៤៩៧២ ដុល្លារ |
| ២ | **ពន្ធ៖** | ០,១៧៩១ ដុល្លារ | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | ០,០២៩៦ ដុល្លារ |
| ៣ | **PREMIUM** | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៨២២ ដុល្លារ | ០,០៧៩៧ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩០៣៧ ដុល្លារ | ០,៨៧៦៥ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៦៩៤ រៀល | ៣.៥៨៣ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩០ ដុល្លារ | ០,៨៨ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៧០០ រៀល | ៣.៦០០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ ដែលស្មើនឹង ៤០៨៨រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៦ កក្កដា ២០១៩ | ៧៣,៨០ | ៧៩,៩៧ |
| ១៧ កក្កដា ២០១៩ | ៧២,៤១ | ៧៨,៨១ |
| ១៨ កក្កដា ២០១៩ | ៧១,៣៩ | ៧៧,៧៩ |
| ១៩ កក្កដា ២០១៩ | ៧១,១១ | ៧៧,៧៩ |
| ២២ កក្កដា ២០១៩ | ៧១,២១ | ៧៩,៤១ |
| ២៣ កក្កដា ២០១៩ | ៦៨,៨១ | ៧៨,៣២ |
| ២៤ កក្កដា ២០១៩ | ៦៨,៤៨ | ៧៩,៥០ |
| ២៥ កក្កដា ២០១៩ | ៦៨,៧២ | ៧៩,០៣ |
| ២៦ កក្កដា ២០១៩ | ៦៨,៩៨ | ៧៨,៧០ |
| ២៩ កក្កដា ២០១៩ | ៦៨,៦៤ | ៧៨,៥៦ |
| ៣០ កក្កដា ២០១៩ | ៦៩,៧៧ | ៧៩,៧៣ |
| ៣១ កក្កដា ២០១៩ | ៧០,៧៩ | ៨១,០១ |
| **មធ្យមភាគ ១២ថ្ងៃ** | **៧០,៣៤២៥** | **៧៩,០៥១៧** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៤៤២៤** | **០,៤៩៧២** |

**ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ខែឧសភា ដល់ ១៦ ខែកក្កដា ឆ្នាំ២០១៩**




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។